# Media Release

Cambodia · Lao PDR · Thailand · Viet Nam
For sustainable development

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

*សម្រាប់ការចុះផ្សាយបន្ទាន់*

## គណៈកម្មការទន្លេមេគង្គ (MRC) នាំយកការពិភាក្សាអំពីគម្រោងដនសាហុងទៅថ្នាក់រដ្ឋមន្ត្រី

*វៀងច័ន្ទ ប្រទេសឡាវ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤* — កម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពនៅថ្ងៃនេះ ថានឹងនាំយកការពិភាក្សាលើគម្រោងថាមពលវារីអគ្គិសនីដនសាហុង ទៅក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ដែលជាស្ថាប័នថ្នាក់រដ្ឋមន្ត្រី មានសមាជិកជារដ្ឋមន្ត្រីក្រសួងធនធានទឹក និងបរិស្ថាន នៃប្រទេសជាសមាជិក។

សមាជិកគណៈកម្មាធិការរួមនៃប្រទេសទាំងបួនបានឈានដល់ការសម្រេចនៅក្នុងសម័យប្រជុំពិសេសមួយដោយបានពិភាក្សាលើគម្រោងថាមពលវារីអគ្គិសនីដនសាហុង ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសឡាវ។ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ រដ្ឋាភិបាលឡាវ បានជូនដំណឹងដល់គណៈកម្មការទន្លេមេគង្គ អំពីការសម្រេចរបស់ខ្លួនដើម្បីធ្វើការរៀបចំគម្រោង និងដាក់ជូន សម្រាប់គោលបំណងនៃការជូនដំណឹងនៅក្រោមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)។ នៅក្នុងការឆ្លើយតបដំបូង កម្ពុជា ថៃ និងវៀតណាម បាននិយាយថាគម្រោងនេះគួរដាក់ជូនសម្រាប់ការការពិគ្រោះយោបល់ជាមុន។ ការជូនដំណឹង ទាមទារឲ្យមានការដាក់ជូនព័ត៌មានពាក់ព័ន្ធអំពីគម្រោងនេះ ដល់ប្រទេសដែលត្រូវទទួលដំណឹង ចំណែកឯ ការពិគ្រោះយោបល់ជាមុនត្រូវការឲ្យមានការពិគ្រោះយោបល់ជាផ្លូវការ និងការវាយតម្លៃបច្ចេកទេស។

ក្រោយការពិភាក្សាអំពីដំណើរការនេះនៅក្រោមនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA), ការប្រជុំនេះមិនបានឈានដល់ការឯកភាពមតិឡើយ អំពីថាតើការជូនដំណឹង ឬដំណើរការពិគ្រោះយោបល់ជាមុន គួរតែអនុវត្តសម្រាប់គម្រោងនេះឬយ៉ាងណា។

គម្រោងដនសាហុងស្ថិតនៅក្នុងស្រុងខុង នៃខេត្តចំប៉ាសាក់ ក្នុងប្រទេសឡាវ និងស្ថិតនៅលើច្រកហ៊ូសាហុងដែលមានប្រវែង ៥គ.ម ពោលគឺជាច្រកផ្លូវទឹកមួយនៃទន្លេមេគង្គ នៅចម្ងាយប្រមាណ ២គ.ម ភាគខាងលើព្រំប្រទល់រវាងប្រទេសឡាវ និងកម្ពុជា។ នៅក្នុងកិច្ចប្រជុំនេះ កម្ពុជា ថៃ និងវៀតណាម ទទូចឲ្យមានដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងនេះ។ ប្រទេសទាំងនេះបានលើកឡើងនូវកង្វល់នានាអំពីផលប៉ះពាល់ដែលអាចកើតពីគម្រោងនេះមកលើផ្លូវត្រីបំលាស់ទី ដោយសារច្រកហ៊ូសាហុង គឺជាផ្លូវទឹកចំបងសម្រាប់ត្រីធ្វើចរាចរនៅក្នុងរដូវប្រាំង។ ឡាវបំភ្លឺថា ផ្លូវទឹកចំនួនពីរនៅជិតខាងហ៊ូសាហុង ពោលគឺ ហ៊ូសាដាម និងហ៊ូសាងភៀក អាចប្រើប្រាស់ជាច្រកផ្លូវជំនួសសម្រាប់ត្រីធ្វើចរាចរ។

ប្រធានប្រតិភូកម្ពុជាបានសំដែងការព្រួយបារម្ភអំពីផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមអវិជ្ជមានធ្ងន់ធ្ងរមកលើតំបន់ជាប់គ្នានៅខ្សែទឹកខាងក្រោមក្នុងប្រទេសកម្ពុជា។

លោក តែ ណាវុធ ប្រធានប្រតិភូកម្ពុជា មានប្រសាសន៍ថា "យើងយល់ថា ឯកសារគម្រោងនេះមិនពេញលេញ ហើយការសិក្សានានាមិនបានគិតអំពីបញ្ហាឆ្លងព្រំដែននៅក្នុងប្រទេសនានា ដូចជា កម្ពុជាឡើយ"។ លោកបានបន្ថែមថា "ប្រសិនបើផ្លូវត្រីចចារជំនួស មិនដំណើរការបានល្អ(សម្រាប់ត្រី) ទំនប់នេះនឹងបង្កការប៉ះពាល់មកលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា"។

ប្រទេសថៃមានទស្សនៈដូចគ្នា ដោយបានលើកសំណួរអំពីប្រសិទ្ធភាពនៃច្រកផ្លូវជំនួស និងបានសុំឲ្យមានការពិគ្រោះយោបល់បន្ថែមទៀត ក្នុងចំណោមប្រទេសសមាជិក មុននឹងចាប់ផ្តើមគម្រោងនេះ ដើម្បីបំភ្លឺចំណុចនេះ និងបញ្ហាដទៃទៀត។

ភាគីថៃពោលថា "ប្រទេសថៃស្នើថា គម្រោងនេះត្រូវឆ្លងកាត់ការពិគ្រោះយោបល់ ដើម្បីអនុញ្ញាតឲ្យមានការពិភាក្សាក្នុងចំណោមភាគីដែលពាក់ព័ន្ធ និងក្រុមអ្នកពាក់ព័ន្ធនានា"។

វៀតណាមបានបង្ហាញទស្សនៈប្រហែលគ្នានេះអំពីផលប៉ះពាល់សង្គម-សេដ្ឋកិច្ច និងបរិស្ថាន ដែលរួមទាំងការប្រែប្រួលលំហូរទឹក និងកំទេចកំណកនៅក្នុងទន្លេនេះផងដែរ។

បណ្ឌិត ឡេ ឌុក ដុង ប្រធានប្រតិភូវៀតណាម មានប្រសាសន៍ថា "យើងយល់ថា ផលប៉ះពាល់មកលើជលផលនឹងមានកម្រិតធំធេង។ ឧទាហរណ៍ គេមិនអាចជំនួសផ្លូវទឹកហ៊ូសាហុង ដោយផ្លូវទឹកកែប្រែ សម្រាប់ត្រីធ្វើចរាចរទៅតំបន់ខ្សែទឹកខាងលើបានឡើយ។ ការសិក្សាបន្ថែមទៀតអំពីផលប៉ះពាល់សង្គមដោយសារការបាត់បង់ផលនេសាទគួរតែបានធ្វើឡើង"។

ប្រតិភូពីប្រទេសឡាវបានអះអាងផ្ទុយពីនេះ ដោយពោលថា ការជូនដំណឹងគឺជានីតិវិធីសមស្របដើម្បីជូនដំណឹងដល់ប្រទេសដទៃទៀតអំពីគម្រោងនេះដែលពួកគេពោលថា មិនមែនជាទំនប់នៅលើដៃទន្លេ ឬ នៅលើទន្លេមេឡើយ។ គម្រោងនេះនឹងប្រើប្រាស់ជាបណ្ដោះអាសន្នត្រឹម ១៥% នៃលំហូរទឹកទន្លេមេគង្គ ដូច្នេះនឹងពុំមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើលំហូរទឹកទន្លេមេគង្គឡើយ។

បណ្ឌិត ដាវង្ស ផូនកែវ ប្រធានប្រតិភូឡាវបានពោលថា "ប្រកហ៊ូសាហុង គឺជាប្រកផ្លូវដ៏សំខាន់សម្រាប់ត្រីធ្វើចរាចរនៅរដូវប្រាំង ប៉ុន្តែដោយហេតុថា មានប្រកផ្លូវទឹកមួយចំនួនដែលត្រីអាចធ្វើចរាចរនៅរដូវវស្សា ហើយការស្រាវជ្រាវបង្ហាញថា ប្រកផ្លូវទឹកដទៃទៀតអាចនឹងកែសម្រួល ដើម្បីកែលម្អការធ្វើចរាចរតាមទិសទាំងពីរនៅគ្រប់រដូវ។ លោកបានបន្ថែមថា "ឡាវមានតម្លាភាព និងបានធ្វើអ្វីដែលជាការតម្រូវនៅក្រោមនីតិវិធីនានាក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥"។

សម័យប្រជុំពិសេសនៃគណៈកម្មាធិការរួមនាថ្ងៃនេះ ជាការជួបប្រជុំនៃសមាជិកគណៈកម្មាធិការរួម មន្ត្រីជាន់ខ្ពស់ពីរដ្ឋាភិបាលនៃប្រទេសសមាជិកទាំងបួន និងសមាជិកជាន់ខ្ពស់ពីលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ ។

ចំពោះព័ត៌មានបន្ថែម អំពីគម្រោងដនសាហុង និងការជូនដំណឹងរបស់ប្រទេសឡាវ សូមអានក្នុង៖
http://www.mrcmekong.org/news-and-events/news/lao-pdr-submits-notification-on-don-sahong-hydropower-project/

**កំណត់សំគាល់៖**

គណៈកម្មការទន្លេមេគង្គ (MRC) គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានភារៈទទួលខុសត្រូវកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងដោយនិរន្តរភាពនៃអាងទន្លេមេគង្គ ដោយមានសមាជិកពី កម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះត្រូវបានបង្កើតឡើង ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសសមាជិក ដូច្នេះមិនមែនជាស្ថាប័នខ្ពស់ជាងថ្នាក់ជាតិ ឬនិយ័តកម្មឡើយ។

នៅក្នុងការដោះស្រាយការប្រឈមនេះ គណៈកម្មការនេះពិនិត្យមើលវិស័យទាំងអស់ ដែលរួមទាំង ការទ្រទ្រង់និរន្តរភាពជលផល កំណត់អត្តសញ្ញាណឱកាសសម្រាប់កសិកម្ម ការរក្សាសេរីភាពក្នុងការធ្វើនាវាចរ ការគ្រប់គ្រងទឹកជំនន់ និងការថែរក្សាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ។ បន្ថែមលើនេះគឺ ឥទ្ធិលទៅអនាគតនៃទឹកជំនន់មិនប្រក្រតីទៅអនាគត គ្រោះរាំងស្ងួតអូសបន្លាយ និងកំណើនកំពស់ទឹកសមុទ្រ ដែលទាក់ទងជាមួយការប្រែប្រួលអាកាសធាតុ។ នៅក្នុងការផ្ដល់យោបល់នេះ គណៈកម្មការទន្លេមេគង្គ មានបំណងសម្រួលឲ្យមានការសន្ទនាទូលំទូលាយក្នុងចំណោមរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ផ្ដល់សេវាបច្ចេកទេស ការណែនាំ និងរដ្ឋបាល ដល់រដ្ឋជាសមាជិក។ ស្ថាប័ននេះសម្រួលឲ្យមានការជួបប្រជុំនៅថ្នាក់តំបន់នៃប្រទេសសមាជិក និងផ្ដល់យោបល់បច្ចេកទេសអំពីការកសាងផែនការរួម ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ។ ស្ថាប័ននេះធ្វើការជិតស្និទ្ធជាមួយស្ថាប័នសម្របសម្រួលនៅក្នុងប្រទេសទាំងបួន ពោលគឺ គណៈកម្មាធិការទន្លេមេគង្គជាតិ (NMCs) និងស្ថាប័នរដ្ឋដទៃទៀត។ បច្ចុប្បន្ននេះ សាធារណរដ្ឋប្រជាមានិតចិន និងសហភាពមីយ៉ាន់ម៉ា ចូលរួមជាដៃគូសន្ទនារបស់គណៈកម្មការទន្លេមេគង្គ ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ស៊ូរ៉ាសាក់ ក្លាហាន មន្ត្រីទំនាក់ទំនង, ការិយាល័យលេខាធិការដ្ឋាននៅវៀងច័ន្ទ។
ទូរស័ព្ទ៖ +856 20 555 28726
អ៊ីម៉ែល: Surasak@mrcmekong.org